ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ: ០៩៤/១០ កប/ស.ជ.ពា

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No : 390
Date: 20.09.10 Time: 10:25
For : GMAC

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារបានជ្រាបថា យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ ២០១ កប/ប្រក. ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល និងដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ សូមម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានអនុវត្ត ដូចតទៅ:-

១-អនុញ្ញាតឱ្យកម្មករ និយោជិត ទាំងអស់របស់ខ្លួនឈប់សម្រាកដោយមានប្រាក់ឈ្នួល នាឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ក្នុងកំឡុងពេលបីថ្ងៃគឺ ថ្ងៃទី ០៧-០៨ និងថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១០

២-ខិតខំរៀបចំបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ឱ្យបានមុនថ្ងៃបុណ្យភ្ជុំបិណ្ឌ។

បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ពេលទេ សូមអនុញ្ញាតឱ្យកម្មករនិយោជិត ទទួលប្រាក់ឈ្នួលមួយភាគជាបុរេប្រទាន មុនពេលបុណ្យភ្ជុំបិណ្ឌ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានជំនឿជឿជាក់ថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ តាមសេចក្តីជូនដំណឹងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១០

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វង សុត

ចម្លងជូន:
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ